របាយការណ៍ប្រចាំត្រីមាសទី ១ ឆ្នាំ ២០១៥ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តសៀមរាប

## I. ស្ថានភាពរបស់មន្ទីរ

### ១. ការិយាល័យរដ្ឋបាល និង កិច្ចការទូទៅ

បច្ចុប្បន្នមន្ទីរមានបុគ្គលិកក្របខណ្ឌសរុបចំនួន ៧៥ នាក់ ស្ត្រី ១០ នាក់គ្រប់គ្រងដោយប្រធាន ០១ រូប ទទួលបន្ទុកក្តាប់រួម និងអនុប្រធាន ០៦ រូប ក្នុងនោះមានស្ត្រី ០១ រូប មន្ត្រីអណ្តែត ស្រី និងមន្ត្រីកិច្ចសន្យា ០១ ស្រី ។

- ការិយាល័យទាំង ០៩ មាន បុគ្គលិកសរុប ៥៩ នាក់ស្ត្រី ០៨ នាក់
- ការិយាល័យអភិវឌ្ឍន៍ជនបទក្រុង និងស្រុកមានបុគ្គលិកសរុបចំនួន ១១ រូបក្នុងនោះស្ត្រី ចំនួន ០១ រូប
- បានទទួលខិតចូលពីស្ថាប័ន មន្ទីរ ក្រសួង និង អន្តរក្រសួងពាក់ព័ន្ធចំនួន ១៣២ លិខិត ក្នុងនោះលិខិតអញ្ជើញ ៤៧ លិខិត
- បានបញ្ជូលលិខិតចេញទៅអង្គភាពមន្ទីរ / ស្ថាប័ន ថ្នាក់ដឹកនាំខេត្ត ក្រសួង អន្តរក្រសួងពាក់ព័ន្ធ សរុបចំនួន ៦៩ លិខិត ។

### ២. ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ

- ធ្វើរបាយការណ៍សម្រេចទូទាត់ចំណាយថវិការដ្ឋ ឆ្នាំ ២០១៤
- ធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ឆ្នាំ ២០១៤
- បិទបញ្ជីចំណូល- ចំណាយថវិការដ្ឋឆ្នាំ ២០១៤
- រត់ការឯកសារ និងបើកបៀវត្សប្រចាំខែ មករា- មីនា ឆ្នាំ ២០១៥
- រៀបចំធ្វើរបាយការណ៍ចំណាយថវិការដ្ឋប្រចាំខែ មករា- មីនាឆ្នាំ ២០១៥
- ចូលរួមប្រជុំផ្សព្វផ្សាយប្រកាសស្តីពីនិតិវិធី ចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ចូលរួមសិក្ខាសាលាស្តីពី ការអនុវត្តថវិកាកម្មវិធី នៅសណ្ឋាគារិ ខេត្តសៀមរាប
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី គោលការណ៍នៃការគ្រប់គ្រង និងការរៀបចំផែនការធនធានមនុស្សនៅសណ្ឋាគារញ៉ូអង្គរខ្មែរ។

### ៣. អធិការកិច្ច- សវនៈកម្ម÷ (គ្មានសកម្មភាព)

### ៤. ការិយាល័យ ផែនការ - ស្ថិតិ

- បូកសរុបរបាយការណ៍អឌ្ឍមាស និងប្រចាំខែមករា- ខែមីនា និងត្រីមាសទី ១ ឆ្នាំ ២០១៥
- ចូលរួមក្នុងកិច្ចប្រជុំពិនិត្យពិភាក្សា និងផ្តល់យោបល់លើសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ខេត្ត (២០១៥ - ២០១៧)
- ចូលរួមសិក្ខាសាលាស្តីពី សមាហរណកម្ម កម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ២០១៥ - ២០១៧

### ៥. កិច្ចប្រជុំផ្សេងៗ និងទំនាក់ទំនងសាធារណៈ

- ចូលរួមធ្វើសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាលដៃគូ

- ចូលរួមកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សាខេត្ត
- ចូលរួមពិធីប្រកាសតែងតាំងអនុប្រធានសាខាផ្នាក់ដឹកនាំការិយាល័យនៃអង្គភាពសាខាពន្ធដាខេត្ត សៀមរាប
- ចូលរួមសិក្ខាសាលាប្រចាំឆ្នាំស្តីពីកម្មវិធីផែនការសុវត្ថិភាពទឹកផឹកជនបទ
- ចូលរួមសិក្ខាសាលាស្តីពីការបង្ហាញលទ្ធផលនៃការវាយតម្លៃពាក់កណ្តាលអណត្តិនៃផែនការយុទ្ធសាស្ត្រ ២០១៣-២០១៦ របស់អង្គការ ប៉ាដិក (PADEK)
- ចូលរួមពិធីបើក និងបិទសន្និបាតបូកសរុបវាយតម្លៃលទ្ធផលការងារអប់រំ យុវជន និងកីឡានៅទូទាំងខេត្ត ឆ្នាំសិក្សា ២០១៣-២០១៤ និងទិសដៅការងារឆ្នាំសិក្សា ២០១៤-២០១៥
- ចូលរួមពិធីប្រកាសចូលកាន់មុខតំណែងរបស់ប្រធាន អនុប្រធានមន្ទីរ ប្រធាន អនុប្រធានការិយាល័យ នៃមន្ទីរបរិស្ថានខេត្តសៀមរាប
- ចូលរួមកិច្ចប្រជុំលើកទី ៧ អាណត្តិទី ២ ប្រចាំខែមករា ឆ្នាំ ២០១៤ របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គ.ក.ស.ក) ខេត្ត
- ចូលរួមសំណេះសំណាលជាមួយ ឯកឧត្តម សេរី កុសល នៅសាលប្រជុំសាលាខេត្ត
- ចូលរួមប្រជុំសាមញ្ញលើកទី ៩ របស់ក្រុមប្រឹក្សាខេត្ត អាណត្តិទី ២ នៅសាលាខេត្ត
- ចូលរួមពិធីបុណ្យសព ឯកឧត្តម អ៊ិត វ៉ាន់ឌី សមាជិកក្រុមប្រឹក្សាខេត្ត
- ចូលរួមសន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំ ២០១៤ និងទិសដៅការងារឆ្នាំ ២០១៥ នៅសាលាខេត្ត
- ចូលរួមពិធីបុណ្យបញ្ចុះខ័ណ្ឌសីមា នៅវត្តប្រាសាទច័ន្ទរង្សី ឃុំស្វាយសរ ស្រុកវ៉ារិន
- ចូលរួមបុណ្យដង្ហែអដ្ឋិធាតុ ជនរងគ្រោះក្នុងរបបប្រល័យពូជសាសន៍ មកតំកល់នៅចេតិយថ្មី នៅវត្តពោធិវង្ស សង្កាត់គោគចក ក្រុងសៀមរាប
- ចូលរួមជាគណៈអធិបតី និងជាវាគ្មិន ក្នុងវេទិកាសម្រាប់ថ្នាក់ឃុំ
- ចូលរួមគណៈកម្មាធិការនាយកហិរញ្ញប្បទានសុខាភិបាលនៅអាគារភ្នែក នៃមន្ទីរពេទ្យបង្អែក
- ចូលរួមប្រជុំ ស្តីពីស្ថានភាពការងារ ឥណទានក្រសួងអភិវឌ្ឍន៍ជនបទ នៅទីស្តីការក្រសួង
- ចូលរួមប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០១៤ និងទិសដៅអនុវត្តន៍បន្ត ឆ្នាំ ២០១៥ របស់ Red Green Belt-SR នៅសាលប្រជុំសាលាខេត្ត
- ចូលរួមវេទិការពិគ្រោះយោបល់ ផ្នែកឯកជន ស្តីពីការត្រៀមខ្លួនធ្វើសមាហរណកម្ម ទៅក្នុងសមាគមន៍សេដ្ឋកិច្ចអាស៊ាន ឆ្នាំ ២០១៥ នៅសណ្ឋាគារអប្សរាអង្គរសៀមរាប
- ចូលរួមពិធីសម្ពោធមជ្ឈមណ្ឌលសិក្សាសហគមន៍រហាល នៅភូមិរហាល ឃុំតាសៀម ស្រុកស្វាយលើ
- ចូលរួមសិក្ខាសាលាបញ្ចប់សកម្មភាព អនុវត្តដោយអង្គការយូរីដូ ក្រោមគម្រោងឧបត្ថម្ភស្មៀងបន្ទាន់-ហិរញ្ញប្បទានបន្ថែម នៅសណ្ឋាគារខេមរាអង្គរ
- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់តម្រង់ទិសថ្នាក់ជាតិ ស្តីពីក្របខ័ណ្ឌ លទ្ធផលនៃផែនការសកម្មភាពជាតិសម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ នៅសណ្ឋាគារ Le Royal

- ចូលរួមក្នុងពិធីសម្ពោធ សាលាមត្តេយ្យជ្រាវ នៅភូមិជ្រាវ សង្កាត់ជ្រាវ ក្រុងសៀមរាប
- ចូលរួមប្រជុំសាមញ្ញលើកទី ១០ របស់ក្រុមប្រឹក្សាខេត្តអាណត្តិទី ២ នៅសាលប្រជុំសាលាខេត្ត
- ចូលរួមវេទិកាសាធារណៈដើម្បីត្រួតពិនិត្យគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ នៅវត្តធិបតី ឃុំត្រីញ័រ ស្រុកពួក ខេត្តសៀមរាប
- ចូលរួមវេទិកាសាធារណៈថ្នាក់ស្រុក ក្រោមប្រធានបទ (ការផ្តល់សេវារដ្ឋបាល និងការទប់ស្កាត់បទល្មើសព្រៃឈើ នៅវត្តបឹងមាលា
- ចូលរួមធ្វើជាវាគ្មិនសន្ទនាមតិ **នាទីស្រុកយើង** (ស្តីពីប្រសិទ្ធិភាពនៃការជួសជុលផ្លូវជនបទ)
- ចូលរួមសិក្ខាសាលាបើកគម្រោងសាកល្បង ស្តីពីការបង្កើនសមត្ថភាព ដើម្បីកាត់បន្ថយ ហានីភ័យ នៃគ្រោះមហន្តរាយក្នុងប្រទេសកម្ពុជា។
- ចូលរួមព្រះរាជពិធីបុណ្យរំលឹកព្រះគុណូបការៈសម្តេចព្រះមហាសុមេធាធិបតី ជួន ណាត ជោតញាណោ សម្តេចព្រះសង្ឃរាជថ្នាក់ទី ១ និងក្រុមជុំនុំព្រះត្រៃបិដកខ្មែរ។
- ចូលរួមប្រជុំផ្សព្វផ្សាយ សេចក្តីណែនាំអន្តរក្រសួង លេខ ៤៩៧ មស.សណន
- ចូលរួមពិធីសន្និបាតបូកសរុប ការងារឆ្នាំ ២០១៤ និងទិសដៅបន្តឆ្នាំ ២០១៥ របស់មន្ទីរសុខាភិបាល នៅសាលប្រជុំសាលាខេត្ត
- ចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាល ស្តីពីការប្រើប្រាស់ទឹក និងអនាម័យ ស្រុកសូទ្រនិគម
- ចូលរួមក្នុងទិវាទឹកពិភពលោកឆ្នាំ ២០១៥ និងប្រគល់ប្រព័ន្ធចំរោះទឹកស្អាតដល់សាលាចំនួន ២៤ ក្នុងខេត្តសៀមរាប
- ចូលរួមប្រជុំផ្សព្វផ្សាយប្រកាសស្តីពីការ បង្កើត ក្រុមលទ្ធកម្មរបស់អង្គភាពថវិកា នៅសាលប្រជុំទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចូលរួមកិច្ចប្រជុំពិភាក្សាជាមួយក្រុមហ៊ុនទិសិន ស្តីពីការប្រើប្រាស់ភ្លើងបំភ្លឺសាធារណៈ ក្នុងក្រុងសៀមរាប
- ចូលរួមក្នុកពិធីជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយគណៈប្រតិភូ គណៈកម្មាធិការអចិន្ត្រៃយ៍សភាជាតិថៃ ដឹកនាំដោយ H.E. Tuang Untachai ប្រធានគណៈកម្មាធិការ
- ចូលរួមសិក្ខាសាលាស្តីពីសមាហរណកម្ម កម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ២០១៥ - ២០១៧
- ចូលរួមប្រជុំពិភាក្សាការងារជាមួយមន្ត្រីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលប្រជុំសាលាខេត្ត
- ចូលរួមជាគណៈអធិបតី ក្នុងទិវាទឹកពិភពលោក នៅភូមិសំបួរ ឃុំរើល ស្រុកពួក
- ចូលរួមកិច្ចប្រជុំស្តីពីការចុះសួរសុខទុក្ខកងទ័ព ក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរ សាលប្រជុំសាលាខេត្ត
- ចូលរួមប្រជុំផ្សព្វផ្សាយប្រកាស ស្តីពីនិតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋ បាលថ្នាក់ជាតិ
- ចូលរួមវេទិកាសាធារណៈ ស្រុកជីក្រែងស្តីពីបរិស្ថានអនាម័យបណ្តាញទឹកស្អាត និងបណ្តាញអគ្គិសនី

## III. សកម្មភាពតាមវិស័យ

### ១.ការងារផ្លូវជនបទ

#### ១.១. ថវិកាក្រសួងអភិវឌ្ឍន៍÷

- ចុះពិនិត្យស្ថានភាពផ្លូវបានសាងសង់រួចរបស់គម្រោងកែលម្អផ្លូវជនបទ (RRIP/ADB) ចំនួនមួយខ្សែ ស្ថិតនៅស្រុកអង្គរធំ-អង្គរជុំ និងស្រុកវ៉ារិន

- ចុះពិនិត្យស្ថានភាពផ្លូវបានសាងសង់រួចរបស់គម្រោង ស្តារឡើងវិញផ្លូវខូចខាតដោយទឹកជំនន់ ឆ្នាំ ២០១១ និងឆ្នាំ ២០១៣

**១.២. គម្រោងកែលម្អផ្លូវជនបទ (RRIP)**

- ផ្លូវពីខ្នាស់-ចាន់សរ ស្រុកសូទ្រនិគម ប្រវែង ១៧ គ.ម
- ផ្លូវពីស្រុកពួក-ស្រុកអង្គរជុំ ប្រវែង ២៩,៥ គ.ម

**១.៣. គម្រោកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទ (RIP)** (គ្មានសកម្មភាព)

**១.៤. គម្រោងឧបត្ថម្ភស្បៀងបន្ទាន់ ជំហាន ២ (EFAP II)**

☐ **គម្រោងសំណង់ស៊ីវិល (CVW)**

- ផ្លូវគ្រួសក្រហម ពីឈូក-ចំបក់សរ ឃុំត្រីញ័រ ប្រវែង **៥ គ.ម** បានបញ្ចប់
- ផ្លូវគ្រួសក្រហម ពីគោគដូង-ស្វាយឃុំត្រីញ័រ ប្រវែង **១,២៥ គ.ម** អនុវត្តបាន ៥០%
- ផ្លូវគ្រួសក្រហម ពីថ្នាស-ធិបតី ឃុំត្រីញ័រ ប្រវែង **២,០៥ គ.ម** អនុវត្តបាន ៥០%
- ផ្លូវគ្រួសក្រហម ភូមិកំភេម ឃុំកែវពិណ ប្រវែង **១ គ.ម** អនុវត្តបាន ៥០%
- ផ្លូវគ្រួសក្រហម ភូមិស្វាយ ឃុំខ្នាត ប្រវែង **១,៥៩ គ.ម** អនុវត្តបាន ៥០%
- ផ្លូវគ្រួសក្រហម ពីបង្កោង-ត្នោត សង្កាត់អំពិល ប្រវែង **២ គ.ម** អនុវត្តបាន ៥០%
- ផ្លូវគ្រួសក្រហម ភូមិត្រពាំងរុន សង្កាត់អំពិល ប្រវែង **២,១ គ.ម** អនុវត្តបាន ៥០%
- ផ្លូវគ្រួសក្រហម ភូមិរលួសលិច ឃុំរលួស ប្រវែង **១ គ.ម** អនុវត្តបាន ៥០%
- ផ្លូវគ្រួសក្រហម ភូមិបំពេញរាជ -ស្វាយ-តាប្រុក ប្រវែង **៤ គ.ម** អនុវត្តបាន ៥០%

☐ **គម្រោងសាច់ប្រាក់ពលកម្ម (CFW)**

- ជួសជុលផ្លូវដីសរ ភូមិតាប្រុក ឃុំលាងដៃ ប្រវែង ១ ០០០ ម
- ជួសជុលផ្លូវដីសរ ភូមិត្រពាំងស្វាយ ឃុំលាងដៃ ប្រវែង ១ ៥៥៥ ម
- ជួសជុលផ្លូវដីសរ ភូមិដូនឪ ឃុំលាងដៃ ប្រវែង ១ ៣០២ ម
- ជួសជុលផ្លូវដីសរ ភូមិត្រីញ័រ ឃុំត្រីញ័រ ប្រវែង ១ ៣២១ ម
- ជួសជុលផ្លូវដីសរ ភូមិចំបក់សរ ឃុំត្រីញ័រ ប្រវែង ៧០០ ម
- ជួសជួលផ្លូវដីសរ ភូមិគោគចាន់ សង្កាត់អំពិល ប្រវែង ១ ១៦៨ ម

## ២. ការខារផ្គត់ផ្គង់ទឹក៖

**២.១. ថវិកាក្រសួងអភិវឌ្ឍន៍ ÷** (គ្មានសកម្មភាព)

**២.២. គម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទជំហានទី ២** (គ្មានសកម្មភាព)

**២.៣. កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានរបស់អង្គការយូនីសេហ្វ**

- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការប្រមូលពត៌មានអណ្តូង តាមទូរសព្ទ័ដៃ នៅខេត្តបាត់ដំបង

- នៅថ្ងៃទី ២៩-៣០ ខែ មករា ឆ្នាំ ២០១៥ បើកវគ្គបណ្តុះបណ្តាល ការប្រមូលពតិមាន អណ្តូង តាមរយៈទូរសព្ទ័ដៃ នៅមន្ទីរអភិវឌ្ឍជនបទខេត្តសៀមរាប ដោយមានការចូលរួមសរុប ២០ នាក់ មកពី មន្ត្រីស្រុកទាំងអស់ មន្ត្រីទឹកស្អាត
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការប្រមូលទិន្នន័យអណ្តូង តាមរយៈទូរសព្ទ័ដៃ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តបាត់ដំបង
- ចូលរួមសម្របសម្រួលវគ្គបណ្តុះបណ្តាល ស្តីពីការប្រមូលទិន្នន័យអណ្តូងតាមរយៈទូរសព្ទ័ដៃ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តសៀមរាប
- ចុះស្រង់ទិន្នន័យអណ្តូង បានចុះស្រង់ទិន្នន័យអណ្តូងបាន ចំនួន ១៩២ អណ្តូង ក្នុង ២៩ ភូមិ ០៥ ឃុំ ២ស្រុក
- ចុះត្រួតពិនិត្យក្រុមហ៊ុន ជួសជុលនិងថ្មីស្តារអណ្តូងទឹកស្អាត របស់អង្គការយូនីសេហ្វ បានចំនួនសរុប ២៣អណ្តូង ក្នុងនោះលើកឃឿនអណ្តូងកម្ពស់ ៧២ ស.ម បានចំនួន ០៥ អណ្តូង ក្នុងស្រុកស្វាទ្រនិគមន៍ និងស្រុកជីក្រែង
- បានចុះត្រួតពិនិត្យក្រុមហ៊ុន ជួសជុលនិងថ្មីស្តារអណ្តូងទឹកស្អាត យកទិន្នន័យអណ្តូងតាមទូរសព្ទ័ដៃ ហើយយកទឹកអណ្តូង ទៅធ្វើតេសគុណភាពទឹក បានចំនួនសរុប ២៥ អណ្តូង ក្នុងស្រុកស្វាទ្រនិគមន៍ និងស្រុកជីក្រែង
- មន្ត្រីទឹកស្អាតនៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត និងមន្ត្រីបច្ចេកទេសទឹកស្អាតថ្នាក់ជាតិ បានចុះត្រួតពិនិត្យការថ្មីស្តារ និងលើកឃឿនអណ្តូងនៅក្នុងស្រុកស្វាទ្រនិគមន៍ និងស្រុកជីក្រែង

## ៣. ការងារថែទាំសុខភាព

### ៣.១. គម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទដំណាក់កាលទី ២ (គ្មានសកម្មភាព)

### ៣.២. កម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមជំនួយហិរញ្ញប្បទានរបស់អង្គការយូនីសេហ្វ

- ការអនុវត្តកម្មវិធីផ្សព្វផ្សាយ ការលើកកម្ពស់អនាម័យតាមវិទ្យុ ៩៥,៥ មេហ្គាហឺត ខេត្តសៀមរាប ត្រូវបានបញ្ចប់ ដោយអនុវត្តន៍ចាប់ពីថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០១៤ ដល់ ថ្ងៃទី ១៣ ខែមករា ឆ្នាំ ២០១៥ ។ ការផ្សព្វផ្សាយជារៀងរាល់ថ្ងៃចន្ទ័ ដល់ថ្ងៃអាទិត្យ មានរយៈពេល ៥០ នាទី ចាប់ពីម៉ោង ៩:០៥ នាទីព្រឹក ដល់ម៉ោង ៩:៥៥ នាទីព្រឹក ។ ការផ្សព្វផ្សាយសំខាន់គឺផ្តោតទៅលើការលើកកម្ពស់អនាម័យនៅជនបទតាមរយៈការឆ្លើយសំនួររបស់ប្រជាជនដែលទូរសព្ទ័ចូលបានបង្ហាញថាការយល់ដឹងផ្នែកអនាម័យមានការកើនឡើង

- ចូលរួមកិច្ចប្រជុំ ស្តីពីការពិនិត្យឡើងវិញនូវការអនុវត្តកម្មវិធីឆ្នាំ ២០១៤ និងការលើកផែនការ ឆ្នាំ ២០១៥ នៅសណ្ឋាគារខេមរា ខេត្តបាត់ដំបង

- បានចុះប្រជុំត្រីមាសទី ០៤ ឆ្នាំ ២០១៤ ក្នុងឃុំគោលដៅទាំង០៦ ក្នុងស្រុកវ៉ារិន និងស្រុកស្រីស្នំ ដោយមានអ្នកចូលរួម សរុប ១៤១ ស្រី ២១ ជាលទ្ធផល ការយល់ដឹងរបស់ប្រជាជនពាក់ព័ន្ធនិងការលើកកម្ពស់អនាម័យមានការកើនឡើង ក្នុងឃុំទាំង០៦ សាងសង់បង្គន់បានចំនួន ២ ៤៧៧ បង្គន់

- មន្ត្រីទទួលបន្ទុក CLTS មន្ត្រីអភិវឌ្ឍន៍ជនបទស្រុក ០១ រូប និងមន្ត្រីទទួលបន្ទុកCLTS ថ្នាក់ជាតិបានចុះត្រួតពិនិត្យ និងជម្រុញ ឃុំ ODF ក្នុងឃុំក្លាំងហាយ ស្រុកស្រីស្នំ

- បានចូលរួមប្រជុំស្តីពី ការលើកកម្ពស់អនាម័យជនបទ និងត្រៀមបង្ការទឹកជំនន់ នៅខេត្តកំពង់ឆ្នាំង

- បានចូលរួមទស្សនៈកិច្ចសិក្សាស្តីពី ការលើកកម្ពស់អនាម័យជនបទ នៅភូមិគោលដៅទទួលបានលទ្ធផលជោគជ័យនៅសង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

**៤. ការងារបណ្តុះបណ្តាល ÷**

| ទីកន្លែង | វគ្គបណ្តុះបណ្តាល | សិក្ខាសាលា | ទស្សនកិច្ចសិក្សា | សរុប | ស្រី |
|---|---|---|---|---|---|
| ក្រៅប្រទេស | 0 | ០ | 0 | 0 | 0 |
| ក្នុងប្រទេស | ០ | ៤ | ០ | ៤ | ០ |
| រៀបចំដោយមន្ទីរអ.ជ.ប | 0 | 0 | 0 | 0 | 0 |
| សរុប | ០ | ៤ | ០ | ៤ | ០ |

**៥. ការងារអភិវឌ្ឍន៍សហគមន៍ ÷**

- បណ្តុះបណ្តាលពង្រឹងសមត្ថភាព (គ.អ.ភ) ២ វគ្គ ស្តីពី÷
  - ⊡ ដំណើរការរៀបចំតួនាទី និងភារៈកិច្ច (គ.អ.ភ)
  - ⊡ គោលគំនិតនៃការអភិវឌ្ឍសហគមន៍
  - ⊡ ការធ្វើផែនការ
  - ⊡ ការធ្វើផែនការសកម្មភាពអភិវឌ្ឍន៍ភូមិ
  - ⊡ វិធីសាស្ត្រនៃចលនាភូមិថ្មីរបស់ប្រទេសកូរ៉េ

សិក្ខាកាមចូលរួមមកពី ០៦ ភូមិក្នុងឃុំបឹងមាលាមន្ត្រីក្រុមប្រឹក្សាឃុំ មន្ត្រីកិច្ចការនារីស្រុក និងមន្ត្រីពេទ្យសត្វស្រុកស្វាយលើ សរុប ៥៤ នាក់ ស្ត្រី ២៣ នាក់ ។

**៦. ការងារសេដ្ឋកិច្ច÷**

**គម្រោងឥណទានគាំទ្រសុខភាពសហគមន៍÷**

អនុវត្តន៍ក្នុងតំបន់គោលដៅចំនួន **៩ភូមិ ៧ឃុំ** ៣ស្រុក សមាជិកខ្ចីទុន **៣៦៩នាក់ ស្រី៣១៩នាក់ (៨១** ក្រុម) ប្រើប្រាស់ទៅលើមុខរបរសំខាន់ៗ ៣គឺ÷ កសិកម្ម, ជំនួញតូចតាច និងសិប្បកម្ម។

| | | | |
|---|---|---|---|
| ទុនដើមឆ្នាំ | **២៥២ ៥០០ ០០០ ៛** | សងរំលោះក្នុងខែ+ផ្តាច់ | ១ ១៩០ ០០០ ៛ |
| ទុនកំពុងចរាចរ | **២៦០ ០៥០ ០០០ ៛** | ការប្រាក់ប្រមូលបាន | ៛ |
| ប្រាក់ជំពាក់ចុងខែ | ៛ | សងរំលោះក្នុងខែ | ៛ |

**៧. ការងារយេនឌ័រ**

- ចូលរួមកិច្ចប្រជុំលើកទី ៧ អាណត្តិទី ២ ប្រចាំខែមករា ឆ្នាំ ២០១៤ របស់គណៈកម្មាធិការពិគ្រោះយោបល់ កិច្ចការស្ត្រី និងកុមារ (គ.ក.ស.ក) ខេត្ត
- ចូលរួមកិច្ចប្រជុំលើកទី ៩ អាណត្តិទី ២ ប្រចាំខែមីនា ឆ្នាំ ២០១៤ របស់គណៈកម្មាធិការពិគ្រោះយោបល់ កិច្ចការស្ត្រី និងកុមារ (គ.ក.ស.ក) ខេត្ត

**VII.សន្និដ្ឋាន**

លទ្ធផលការងារដែលសម្រេចបានខាងលើនេះ គឺពិតជាបានមកដោយសារការចង្អុលបង្ហាញពីរថ្នាក់ដឹកនាំក្រសួងនិងការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំមន្ទីរ និងបុគ្គលិកគ្រប់លំដាប់ថ្នាក់ដែលបានយកចិត្តទុកដាក់សហការជាមួយអាជ្ញាធរមូលដ្ឋាន និងទទួលខុសត្រូវខ្ពស់ក្នុងការបំពេញការងារ រហូតទទួលបានលទ្ធផលជោគជ័យ។ តែទោះជាយ៉ាងណាក្តីលទ្ធផលការងារទាំងនេះនៅពុំទាន់បានឆ្លើយតបទាំងស្រុងនូវផែនការដែលបានគ្រោងទុក ដែលទាំងនេះ ទៀមទាឲ្យមានការជ្រោមជ្រែងបន្ថែមទាំងសម្ភារ និងថវិកាដើម្បីបំពេញការងារឲ្យបានជោគជ័យតាមផែនការ ដែលបានគ្រោងទុក៕

ប្រធានមន្ទីរ